## ២. ស្ថានភាពបំពេញការងារវិស័យអប់រំឆ្នាំ ២០០១-២០០៥

នៅក្នុងផ្នែកនេះនឹងរៀបរាប់ពីអ្វីដែលក្រសួងអប់រំ យុវជន និង កីឡា សម្រេចបានតាមគោលនយោបាយនានា ដូចជា ការធានាសមធម៌ក្នុងការទទួលសេវាអប់រំ ការលើកកំពស់គុណភាពនិងប្រសិទ្ធភាពនៃការអប់រំ និងការអភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាព ធៀបនឹងចំណុចដៅដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យ អប់រំឆ្នាំ ២០០៤-២០០៨ ។

### ២.១ ការទទួលបានសេវាអប់រំប្រកបដោយសមធម៌

តារាងទី ១ និងដ្យាក្រាមទី ១ ខាងក្រោមបង្ហាញថា អត្រាពិតនៃការសិក្សាសរុបនៅបឋមសិក្សា ជិតសម្រេចបានតាមចំណុចដៅ ៩២% និងសំរាប់សិស្សស្រី ៩១% ។ គួរកត់សំគាល់ថា អត្រានេះបានកើនឡើងខ្លាំង ជាពិសេសនៅតំបន់ដាច់ស្រយាល និងតំបន់ជនបទ ។ បើប្រៀបធៀបឆ្នាំសិក្សា ២០០០-០១ និងឆ្នាំសិក្សា ២០០៤-០៥ អត្រាពិតនៃការសិក្សាសរុប បានកើនឡើងជាង ២០% នៅតំបន់ដាច់ស្រយាល ឯនៅតំបន់ជនបទកើនបាន ៨% ហើយនៅតំបន់ប្រជុំជនវិញកើនបានប្រមាណតែ ៥% ប៉ុណ្ណោះ ក្នុងរយៈពេលដូចគ្នា ។

ចំពោះការចូលរៀននៅមធ្យមសិក្សាបឋមភូមិវិញ ពុំសូវកើនឡើងច្រើនដូចការរំពឹងទុកក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៤-០៨ ទេ គឺប្រមាណ ៦៦% បានចូលរៀននៅឆ្នាំ ២០០៤-០៥ ច្រើនជាងឆ្នាំ សិក្សា ២០០០-០១ ។ ទោះជាយ៉ាងណាក៏ដោយ អត្រាពិតនៃការសិក្សាពុំអាចសំរេចបានតាមចំណុចដៅកំណត់ ៤០% នៅឆ្នាំសិក្សា ២០០៤-០៥ នោះទេ (សូមមើលដ្យាក្រាមទី ១) ។ ការពិនិត្យមើលចំនួនសិស្សតាមថ្នាក់នីមួយៗនៃបឋមសិក្សាដែលត្រូវទៅរៀននៅមធ្យមសិក្សាបឋមភូមិ តម្រូវអោយមានការវាយតម្លៃកាន់តែទូលំទូលាយថែមទៀតលើអត្រាបញ្ចប់ការសិក្សា និងអត្រាឆ្លងភូមិសិក្សានៅបឋមសិក្សា ដើម្បីជាមូលដ្ឋានក្នុងការកំណត់ចំណុចដៅសម្រាប់មធ្យមសិក្សាបឋមភូមិនាពេលអនាគត ។ អត្រាពិតនៃការសិក្សារបស់សិស្សនៅតំបន់ដាច់ស្រយាល នៅតែមានកំរិតទាប គឺ ៣.៩% មានន័យថា កុមារវ័យជំទង់អាយុពី ១២-១៤ ឆ្នាំ ជាង ៩៥% ពុំបានចូលរៀននៅមធ្យមសិក្សាបឋមភូមិទេ ពីព្រោះនៅតំបន់ទាំងនោះពុំទាន់មានសាលាមធ្យមសិក្សានៅឡើយ ។ ក្នុងចំណោមឃុំចំនួន ១,៦២១ មានតែ ៧៤៩ ឃុំទេដែលមានអនុវិទ្យាល័យ ។ ចំពោះការចូលរៀននៅមធ្យមសិក្សាទុតិយភូមិវិញ អត្រាពិតនៃការសិក្សា កើនបានតែ ១.៦% ប៉ុណ្ណោះក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ ។

ការអប់រំក្រៅប្រព័ន្ធ និងឧត្តមសិក្សា ពុំបានសម្រេចតាមចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៤-០៨ ទេ (តារាងទី ១) ។ តែទោះបីជាយ៉ាងក៏ដោយ ក៏មានការកត់សំគាល់ឃើញថា ចំនួននិស្សិតដែលបានចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាឯកជន បានកើនឡើងទ្វេដង គឺពី ១៨,០០០ នាក់ ទៅ ៣៩,០០០ នាក់ក្នុងពេល ៥ ឆ្នាំ ។ ចំណែកឯគ្រឹះស្ថានសិក្សាសាធារណៈវិញកើនប្រហែល ១០% ប៉ុណ្ណោះក្នុងរយៈពេលដូចគ្នា ។

និស្សិតនារីដែលសិក្សាបង់ថ្លៃតាមគ្រឹះស្ថានសិក្សានានា មានចំនួនច្រើនជាងចំណុចដៅដែលគ្រោងទុកគឺ ១០,៨០០ នាក់ ក្នុងឆ្នាំសិក្សា ២០០៤-០៥ ។

ដើម្បីសម្រេចចំណុចដៅប្រចាំឆ្នាំនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងឈានទៅសម្រេចគោលដៅរយៈពេលវែងរបស់គោលដៅអភិវឌ្ឍន៏សហសវត្សរ៏កម្ពុជា និងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា តម្រូវអោយមានការប្រឹងប្រែងជាច្រើនថែមទៀត ជាពិសេសត្រូវពង្រីកសេវាបន្ថែមទៀតសំរាប់មធ្យមសិក្សា ។

### តារាងទី ១ : សមិទ្ធផលធៀបនឹងចំណុចដៅនៃសមធម៌នៃការចូលរៀន

| អាំងឌីកាទ័រ | ជាក់ស្តែង **2000-01** | | ជាក់ស្តែង **2004-05** | | ចំណុចដៅ **2004-05** | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| **អត្រាពិតចូលរៀនថ្មីទូទាំងប្រទេស** | 76.4% | 74.9% | 81.0% | 79.5% | 90% | 90% |
| **អត្រាពិតនៃការសិក្សា** | | | | | | |
| **បឋមសិក្សា : ទូទាំងប្រទេស** | **83.8%** | **80.7%** | **91.9%** | 90.7% | **92%** | **91%** |
| បឋមសិក្សា : តំបន់ប្រជុំជន | 86.4% | 83.2% | 91.6% | 90.4% | 95% | 94% |
| បឋមសិក្សា : តំបន់ជនបទ | 84.1% | 81.0% | 92.4% | 91.2% | 92% | 91% |
| បឋមសិក្សា : តំបន់ដាច់ស្រយាល | 62.3% | 58.2% | 82.5% | 79.4% | 76% | 75% |
| **មធ្យមសិក្សាបឋមភូមិ : ទូទាំងប្រទេស** | **16.6%** | **13.7%** | **26.1%** | **24.8%** | **40%** | **39%** |
| មធ្យមសិក្សាបឋមភូមិ : តំបន់ប្រជុំជន | 29.5% | 26.8% | 41.3% | 40.5% | 50% | 49% |
| មធ្យមសិក្សាបឋមភូមិ : តំបន់ជនបទ | 14.1% | 11.0% | 23.7% | 22.2% | 35% | 34% |
| មធ្យមសិក្សាបឋមភូមិ : តំបន់ដាច់ស្រយាល | 1.2% | 1.0% | 3.9% | 4.1% | 15% | 15% |
| **មធ្យមសិក្សាទុតិយភូមិ** | 7.7% | 5.4% | 9.3% | 7.9% | 15% | 14% |
| **អត្រាឆ្លងភូមិសិក្សា** | | | | | | |
| - ទៅមធ្យមសិក្សាបឋមភូមិ | 77.3% | 71.1% | 81.9% | 79.6% | 87% | 85% |
| - ទៅមធ្យមសិក្សាទុតិយភូមិ | 56.2% | 57.9% | 56.1% | 58.0% | 64% | 66% |
| ចំនួនសិស្សក្នុងកម្មវិធី NFE/CLLC (កម្មវិធីសមមូលពេញម៉ោង) | - | - | 141,561 | 80,171 | 220,000 | 132,000 |
| ចំនួននិស្សិតគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ: | 7,291 | 1.890 | 7,953 | 2,802 | 20,000 | 6,000 |
| - ចំនួននិស្សិតអាហារូបករណ៍ | - | - | - | - | 8,500 | 3,000 |
| ចំនួននិស្សិតឧត្តមសិក្សាបង់ថ្លៃ | 18,125 | 5,060 | 38,882 | 12,685 | 49,000 | 10,800 |
| ចំនួនគរុនិស្សិតនៅសាលាគរុកោសល្យ | 8,302 | 3,377 | 6,520 | 2,512 | 10,000 | 3,600 |

ដ្យាក្រាមទី ១ : សមិទ្ធផលធៀបនឹងចំណុចដៅរបស់អត្រាពិតនៃការសិក្សានៅឆ្នាំសិក្សា ២០០៤-២០០៥




## ២.២ គុណភាព និងប្រសិទ្ធភាពសេវាអប់រំ

តារាងទី២ ខាងក្រោម បង្ហាញពីអាំងឌីកាទ័រនៃសមិទ្ធផលមួយចំនួនទាក់ទងនឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំ ធៀបនឹងចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៤-០៨ ។ ក្រសួងអប់រំ យុវជន និងកីឡា ពុំទាន់បានបង្កើតប្រព័ន្ធវាយតម្លៃការសិក្សាគំរូ សំរាប់វាស់ស្ទង់លទ្ធផលសិក្សា ដើម្បីដឹងពីគុណភាព និងលទ្ធផលនៃការបង្រៀន និងរៀន អោយបានប្រាកដនៅឡើយទេ ដែលនេះជាបញ្ហាប្រឈមមួយកំពុងជួបប្រទះ ។ តែទោះជាយ៉ាងណាក៏ដោយ តាមរយៈអាំងឌីកាទ័រមួយចំនួនបានបង្ហាញថា ការវិវឌ្ឍនៅមិនទាន់សម្រេចបានតាមចំណុចដៅដែលកំណត់ទុកនៅឡើយ ពោលគឺ អត្រាឡើងថ្នាក់ទាបជាងចំណុចដៅ ជាពិសេសនៅថ្នាក់ទី ១ ។ បើតាមដំណើរវិវឌ្ឍបច្ចុប្បន្ននេះ ចំណុចដៅរយៈពេលវែង នឹងពុំបានសម្រេចឡើយ (សូមមើលដ្យាក្រាមទី ២) ។ ស្រដៀងគ្នានេះដែរ អត្រាត្រួតថ្នាក់នៅតែខ្ពស់ដដែល ជាក់ស្តែង នៅថ្នាក់ទី ១ ហើយការប្រែប្រួលរបស់វាយឺតទៀតផង ។ រយៈពេល ៥ ឆ្នាំកន្លងមកនេះ អត្រាត្រួតថ្នាក់ទី ១ ថយបាន ៤.៩% អត្រាត្រួតថ្នាក់ ទី ២ ថយបាន ១.៥% និងអត្រាត្រួតថ្នាក់ទី ៣ ថយបាន ២.៨% ។ តាមស្ថានភាពអត្រាត្រួតថ្នាក់នេះបង្ហាញថា ការសម្រេចគោលដៅរយៈពេលវែងនៃការអប់រំសម្រាប់ទាំងអស់គ្នា ពិតជាជួបការលំបាកណាស់ ។

ជាមួយគ្នានោះដែរ ក្នុងរយៈពេល ៥ ឆ្នាំនេះ កំរិតអប់រំរបស់គ្រូបង្រៀនបានកែលំអជាបន្តបន្ទាប់ (តារាងទី ២) ។ សមាមាត្រគ្រូបង្រៀន ដែលបានទទួលការអប់រំយ៉ាងតិចមធ្យមសិក្សាបឋមភូមិ បានកើនឡើងពី ២៦%

ក្នុងឆ្នាំសិក្សា ២០០០-០១ ដល់ ៣៦% ក្នុងឆ្នាំសិក្សា ២០០៤-០៥ ។ ប៉ុន្តែ ទោះបីមានការរីកចំរើនខ្លាំងក៏ដោយ ក៏ពុំទាន់ដល់ចំណុចដៅ ៥១% ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំដែរ ។

ទោះក្នុងកាលៈទេសៈណាក៏ដោយ ដើម្បីវាស់វែងការរីកចំរើនលើគុណភាព និងប្រសិទ្ធភាពសេវាអប់រំឱ្យបានត្រឹមត្រូវ ចាំបាច់ត្រូវប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ និងរៀបចំអាំងឌីកាទ័រឱ្យបានប្រាកដប្រជា ។ ការចាប់ផ្តើមដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃការសិក្សារបស់សិស្សតាមស្តង់ដា ព្រមទាំងប័ណ្ណរាយការណ៍របស់សាលារៀន នឹងអាចធ្វើឱ្យការពិនិត្យតាមដានលើគុណភាពសេវាអប់រំ កាន់តែច្បាស់លាស់ចាប់ពីឆ្នាំសិក្សា២០០៦-០៧ តទៅ ។

**តារាងទី ២ : សមិទ្ធផលធៀបនឹងចំណុចដៅនៃគុណភាព និង ប្រសិទ្ធភាពសេវាអប់រំ**

| អាំងឌីកាទ័រ | ជាក់ស្តែង 2000-01 | | ជាក់ស្តែង 2004-05 | | ចំណុចដៅ 2004-05 | |
|---|---|---|---|---|---|---|
| ផលធៀបសិស្ស-គ្រូ | | | | | | |
| - បឋមសិក្សា | 53.3 | | 53.5 | | 51.0 | |
| - មធ្យមសិក្សាបឋមភូមិ | 18.3 | | 27.7 | | 26.0 | |
| - មធ្យមសិក្សាទុតិយភូមិ | 25.3 | | 29.4 | | 28.0 | |
| អត្រាឡើងថ្នាក់ | សរុប (1999-00) | ស្រី | សរុប (2003-04) | ស្រី | សរុប | ស្រី |
| ថ្នាក់ទី១ | 60.9% | 60.9% | 64.8% | 65.4% | 88% | 88% |
| ថ្នាក់ទី២ | 71.5% | 72.4% | 73.4% | 74.8% | 89% | 89% |
| ថ្នាក់ទី៣ | 73.9% | 75.0% | 77.3% | 78.9% | 88% | 89% |
| អត្រាត្រួតថ្នាក់ | សរុប (1999-00) | ស្រី | សរុប (2003-04) | ស្រី | សរុប | ស្រី |
| ថ្នាក់ទី១ | 28.5% | 27.5% | 23.6% | 22.4% | 6% | 6% |
| ថ្នាក់ទី២ | 17.6% | 16.4% | 16.1% | 14.4% | 5% | 4% |
| ថ្នាក់ទី៣ | 15.0% | 13.5% | 13.2% | 11.3% | 5% | 5% |
| ចំណាយលើសម្ភារៈបង្រៀនសម្រាប់សិស្សម្នាក់ (គិតជារៀល) | - | | - | | 5,800 | |
| ចំនួនសាលារៀនបឋមសិក្សាមិនគ្រប់កំរិតថ្នាក់ | 2,484 | | 1,934 | | 1,800 | |
| % គ្រូបង្រៀនបានរៀនដល់ថ្នាក់ទី ១០-១២ ឬ លើសពីនេះ | 26.0% | | 36.0% | | 51% | |
| ចំនួនគ្រូបង្រៀនចេញថ្មីទៅបំរើការងារនៅតំបន់ដាច់ | - | | - | | 4,500 | |

| | | | |
|---|---|---|---|
| ស្រយាល/ជួបការលំបាក | | | |
| ចំនួនសិស្សបានប្រឡងជាប់ថ្នាក់ទី ១២ | 17,713 | 18,883 | 25,000 |
| ចំនួយសិស្សបានចូលរៀនឡើងវិញពីថ្នាក់ទី ៣-៩ | | | 30,000 |
| % គ្រឹះស្ថានសិក្សាសាធារណៈ/ឯកជនដែលបានពិនិត្យគុណភាព | | | 15% |
| ចំនួនសាលារៀន/សាលាគរុកោសល្យ ដែលមានសម្ភារវិទ្យាសាស្ត្រថ្មី និង ICT | | | 10 |

**ដ្យាក្រាមទី២ : សមិទ្ធផល និងចំណុចដៅនៃអត្រាឡើងថ្នាក់ និងត្រួតថ្នាក់ ឆ្នាំសិក្សា ២០០៤-២០០៥**




## ២.៣ ការអភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការ

លទ្ធផលសំខាន់ៗដែលទទួលបានក្នុងរយៈពេល ៥ ឆ្នាំ លើផ្នែកអភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការមានដូចខាងក្រោមនេះ :

- បន្តបង្កើតយន្តការដ៏រឹងមាំមួយនៃការកសាងផែនការ និងការអនុវត្តសកម្មភាពកសាងសមត្ថភាព តាមរយៈក្រុមសម្របសម្រួលកសាងសមត្ថភាព នៅក្រោមអគ្គនាយកដ្ឋានទាំងពីរគឺ អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានអប់រំ ។
- បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអប់រំ និងបានដាក់សុំការអនុម័តពីរដ្ឋសភា ។

- បានពង្រីកកម្មវិធីកសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការ (ដូចជាខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងសាលារៀន) ក្នុងការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ការពិនិត្យតាមដានកម្មវិធី និងការគ្រប់គ្រងព័ត៌មាន ។
- ពង្រីកការប្រើប្រាស់ ICT តាមរយៈគេហទំព័ររបស់ក្រសួងអប់រំ យុវជន និង កីឡា យុទ្ធនាការណែនាំពិគ្រោះយោបល់ផ្សេងៗ និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន ។
- តួនាទី និងភារកិច្ចរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវបានពង្រឹង និងបានធ្វើសវនកម្មគំរូនៅ BMC ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និង សាលារៀនមួយចំនួន ។
- បានកសាងស្តង់ដាអាំងឌីកាទ័រផ្នែកអប់រំកុមារតូច ការអប់រំមូលដ្ឋាន និងបំណិនជីវិតសម្រាប់ពិនិត្យតាមដាន វាយតម្លៃគុណភាពអប់រំលើគ្រប់ទិដ្ឋភាព ។
- បានពង្រឹងការពិនិត្យតាមដានការបំពេញការងារផ្អែកលើលទ្ធផល ដោយប្រើទិន្នន័យរបស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងទិន្នន័យផ្សេងៗទៀត ។
- កំពុង និងបន្តការរៀបចំនីតិវិធីនៃការគ្រប់គ្រង និងចំណាយថវិកា ។
- បានរៀបចំការប្រជុំពិគ្រោះយោបល់យ៉ាងទៀតទាត់ជាមួយខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ពិសេសស្តីពីការគ្រប់គ្រង និងការអនុវត្តថវិកាកម្មវិធីសកម្មភាពជាអាទិភាព ។
- បានពង្រឹងសមត្ថភាពជំនាញក្នុងការកសាង និងអនុវត្តកម្មវិធីសិក្សាថ្មី ទាំងនៅថ្នាក់រដ្ឋបាលកណ្តាល និងថ្នាក់ខេត្ត-ក្រុង ។
- បានពង្រឹងចំណេះដឹង និងជំនាញខាងផែនការ និងគ្រប់គ្រងដល់នាយក និងបុគ្គលិកកំរងសាលារៀន ។
- បានពង្រឹងសមត្ថភាពគ្រប់គ្រង និងរៀបចំកិច្ចការប្រឡងនានា ។
- ពង្រីកការយល់ដឹងពីបញ្ញត្តិ និងការអនុវត្តសាលារៀនកុមារមេត្រី នៅថ្នាក់រដ្ឋបាលកណ្តាល ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និង សាលារៀន ។
- បានកែលំអប្រព័ន្ធគ្រប់គ្រងកម្មវិធីសកម្មភាពជាអាទិភាពមួយចំនួន ។
- បានពង្រឹងការសម្របសម្រួលរវាងរាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាល តាមរយៈការប្រជុំជាទៀងទាត់របស់ក្រុមការងារបច្ចេកទេសចំរុះវិស័យអប់រំ ។

តារាងទី ៣ ខាងក្រោម បង្ហាញពីលទ្ធផលផ្នែកបរិមាណខ្លះៗ ទាក់ទងនឹងការអភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការ ធៀបទៅនឹងចំណុចដៅដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៤-០៨ ដែលភាគច្រើនពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុ ។ ចំណែកថវិកាអប់រំដែលបានទទួលពីរាជរដ្ឋាភិបាលបានកើនឡើងយ៉ាងច្រើនពី ១៣.៩% ក្នុងឆ្នាំសិក្សា ២០០០-០១ ទៅដល់ ១៧.៣% ក្នុងឆ្នាំសិក្សា ២០០៤-០៥ ប៉ុន្តែនៅទាបជាងចំណុចដៅគឺ ១៩.៥% ។ ថវិកាអប់រំសំរាប់កម្មវិធីសកម្មភាពជាអាទិភាព ក៏បានកើនឡើងច្រើន

ផងដែរគឺពី ៥.៥% ទៅដល់ ២៧.៩% ក្នុងរយៈពេល ៥ ឆ្នាំ ដូចគ្នា ដែលកំណើននោះបានជិតដល់ចំណុចដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំហើយ ។ ចំពោះអាំងឌីកាទ័រស្តីពីចំនួនបុគ្គលិកមិនបង្រៀនធៀបជាមួយបុគ្គលិកអប់រំសរុបវិញ ពុំសូវមានការប្រែប្រួលអ្វីទេក្នុងរយៈពេល ៥ ឆ្នាំនេះ ។

ដើម្បីវាយតម្លៃលទ្ធផលនៃការប្រឹងប្រែងអភិវឌ្ឍស្ថាប័ន និង កសាងសមត្ថភាពពីថ្នាក់កណ្តាលដល់ថ្នាក់មូលដ្ឋាន ចាំបាច់ត្រូវកំណត់អាំងឌីកាទ័របន្ថែមទៀត ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និង កម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ ២០០៦-១០ ត្រូវធ្វើការកែលំអក្របខ័ណ្ឌពិនិត្យតាមដាន ដែលអាចវាយតម្លៃបានទៀងទាត់ និង ជិតដល់ជាងមុនទៅលើសមត្ថភាពបុគ្គល និង សមត្ថភាពស្ថាប័ន ក្នុងវិស័យអប់រំ ដូចអាំងឌីកាទ័រដែលបានលើកឡើង ។

**តារាងទី ៣ : សមិទ្ធផលធៀបនឹងចំណុចដៅនៃការអភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាព**

| អាំងឌីកាទ័រ | ជាក់ស្តែង 2000-01 | ជាក់ស្តែង 2004-05 | ចំណុចដៅ 2004-05 |
|---|---|---|---|
| ចំណែកថវិកាចរន្តជាតិសំរាប់វិស័យអប់រំ | 13.9% | 17.3% | 19.5% |
| ចំណាយមិនមែនបុគ្គលិកធៀបនឹងការចំណាយចរន្តសរុប | - | 43% | 40% |
| ចំណែកថវិកាសំរាប់កម្មវិធីសកម្មភាពជាអាទិភាពធៀបនឹងថវិកាសរុបសំរាប់វិស័យអប់រំ | 5.5% | 27.9% | 29% |
| ការចំណាយលើការពិនិត្យតាមដានកម្មវិធីសកម្មភាពជាអាទិភាព (គិតជាពាន់លានរៀល) | - | 3.6 | 6.8 |
| អត្រាបើកផ្តល់សាច់ប្រាក់សំរាប់កម្មវិធីសកម្មភាពចំណាយចរន្ត | - | 96 | 93% |
| ចំនួនអង្គភាពគ្រប់គ្រងថវិកា (BMC)<br>- % BMC ដែលមានបុគ្គលិកបានបណ្តុះបណ្តាលផ្នែកគណនេយ្យ<br>- % BMC មានប្រព័ន្ធព័ត៌មានគ្រប់គ្រងតាមព័ត៌មាន និងបច្ចេកវិទ្យាសារគមនាគមន៍ (ICT) | 64<br>-<br>- | 194<br>-<br>- | 230<br>20%<br>40% |
| ចំនួន BMC ត្រូវធ្វើសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ<br>- % សាលារៀន/គ្រឹះស្ថានសិក្សាដែលត្រូវធ្វើសវនកម្មប្រចាំឆ្នាំ | - | - | 60<br>5% |
| % បុគ្គលិកបង្រៀនសរុប ធៀបនឹងបុគ្គលិកសរុបវិស័យអប់រំ * | 18.1% | 18.8% | 16% |

* *មិនគិតបុគ្គលិកនៅរដ្ឋបាលថ្នាក់កណ្តាល*

**ដ្យាក្រាមទី ៣ : សមិទ្ធផល និងចំណុចដៅនៃការផ្តល់ហិរញ្ញវត្ថុសំរាប់វិស័យអប់រំ**

